**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងលិខិតលេខ ៣៤៤ សជណ.អស ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរួមរបស់ប្រធានតុលាការកំពូល និងប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច
## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._គោលបំណង**

អនុក្រឹត្យនេះមានគោលបំណង ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យច្បាប់នៅក្នុងបណ្តាប្រទេសអាស៊ាន។

**មាត្រា ២._គោលដៅ**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងវិស័យច្បាប់ដើម្បីរួមចំណែក

ធានាការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងវិនិយោគិន ក្នុងតំបន់អាស៊ាន និងទាក់ទាញវិនិយោគបរទេស។

## ជំពូក ២
## គណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជា

**មាត្រា ៣.**_ការបង្កើត

ត្រូវបានបង្កើតគណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជាដែលហៅកាត់ថា“គ.ស.ច្ប.អ.ស៊.ក” ដែលមានប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានគណៈកម្មាធិការ និងមានអនុប្រធានអចិន្ត្រៃយ៍ សមាជិក និងលេខាធិការ តាមការសម្រេចរបស់ប្រធានគណៈកម្មាធិការ។

**មាត្រា ៤.**_ការប្រព្រឹត្តទៅរបស់ គ.ស.ច្ប.អ.ស៊.ក

ការប្រព្រឹត្តទៅរបស់ គ.ស.ច្ប.អ.ស៊.ក ស្ថិតក្រោមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## ជំពូក ៣
## សកម្មភាព និងរចនាសម្ព័ន្ធ

**មាត្រា ៥.**_សកម្មភាព និងតួនាទី

គណៈកម្មាធិការជាតិនៃសមាគមន៍ច្បាប់អាស៊ានកម្ពុជាមានតួនាទី និងភារកិច្ច៖

- បង្កើត និងអនុវត្តស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន
- ចូលរួមប្រជុំប្រជុំ និងធ្វើសកម្មភាពស្របតាមលក្ខន្តិកៈរបស់សមាគមន៍ច្បាប់អាស៊ាន
- ចូលរួមបង្ហាញអំពីទិដ្ឋភាពច្បាប់របស់កម្ពុជាលើឆាកអន្តរជាតិ
- ធ្វើសហប្រតិបត្តិការលើទិដ្ឋភាពច្បាប់របស់ប្រទេសកម្ពុជាជាមួយអ្នកច្បាប់នៃបណ្តាប្រទេសអាស៊ានដទៃទៀត ដើម្បីជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា និងទាក់ទាញវិនិយោគិន និង
- ទទួលរៀបចំព្រឹត្តិការណ៍នៃកិច្ចប្រជុំសមាគមន៍ច្បាប់អាស៊ាន តាមវេន ដោយសម្របសម្រួលជាមួយនឹងកិច្ចប្រជុំក្រុមប្រឹក្សាប្រធានតុលាការកំពូលអាស៊ាន ដោយសហការជាមួយតុលាការកំពូល។

**មាត្រា ៦.**_រចនាសម្ព័ន្ធ និងត្រា

គណៈកម្មាធិការជាតិនេះអាចបង្កើតក្រុមការងារ ស្របតាមរចនាសម្ព័ន្ធការងាររបស់សមាគមន៍ច្បាប់អាស៊ាន។

គណៈកម្មាធិការជាតិនេះមានត្រាប្រើប្រាស់សម្រាប់អនុវត្តការងាររបស់ខ្លួន តាមការកំណត់របស់ប្រធានគណៈកម្មាធិការជាតិនេះ។

គណៈកម្មាធិការជាតិនេះអាចមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ។

**មាត្រា ៧.**_ថវិកា

គណៈកម្មាធិការជាតិនេះទទួលថវិកាឧបត្ថម្ភពីកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាលសម្រាប់ដំណើរ

ការរដ្ឋបាល ការរៀបចំកិច្ចប្រជុំសមាគមន៍ច្បាប់អាស៊ានតាមវេន និងការចូលរួមប្រជុំជាអន្តរជាតិ ។

គណៈកម្មាធិការជាតិនេះត្រូវលើកគម្រោងចំណាយរបស់ខ្លួនជូនរាជរដ្ឋាភិបាល។

## ជំពូក ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨.**_ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.**_ស្ថាប័ន និងបុគ្គលទទួលបន្ទុកអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

ប្រធានតុលាការកំពូល ប្រធានគណៈមេធាវី

**ឌិត មុន្ទី** **សួន វិសាល**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ